អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៧

# សេចក្តីប្រកាសព័ត៌មាន

## ការពិភាក្សាផ្លាស់ប្តូរយោបល់ លើកទីបួន របស់ព្រះរាជអាជ្ញាអន្តរជាតិ - ទីក្រុងភ្នំពេញ ៧ - ៨ វិច្ឆិកា ២០០៧

ព្រះរាជអាជ្ញានៃបណ្តាសាលាក្តីព្រហ្មទណ្ឌអន្តរជាតិ និងកូនកាត់ទាំងអស់ នឹងជួបប្រជុំពិភាក្សាផ្លាស់ប្តូរយោបល់គ្នាមួយនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") នៅទីក្រុងភ្នំពេញ សំរាប់រយៈពេលពីរថ្ងៃ ចាប់ពីថ្ងៃទី ៧ ដល់ថ្ងៃទី ៨ ខែវិច្ឆិកា ឆ្នាំ២០០៧ ។ កិច្ចពិភាក្សានេះនឹងគូសបញ្ជាក់ពីការប្រឈមនានាដែលកំពុងជួបប្រទះក្នុងការកាត់សេចក្តីទៅលើអំពើរំលោភធ្ងន់ធ្ងរចំពោះច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ នៅក្នុងតុលាការនានា ដូចជា អ.វ.ត.ក ជាដើម ។

សហព្រះរាជអាជ្ញានៃ អ.វ.ត.ក គឺ **លោកស្រី ជា លាង** (Chea Leang) និង **លោក រ៉ូប៊ឺត ពីទិត** (Robert Petit) នឹងធ្វើជាម្ចាស់ផ្ទះនៃអង្គសន្និសីទនៃកិច្ចពិភាក្សាផ្លាស់ប្តូរយោបល់នេះ ។ អ្នកចូលរួមមាន **ឡារី ចនសាន់** (Larry Johnson) ជំនួយការរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ សំរាប់កិច្ចការច្បាប់ **ខាឡា ដែល ប៉ុងតេ** (Carla Del Ponte) អគ្គព្រះរាជអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់អតីតយូហ្គោស្លាវី **ហាស់សាន់ ចាលឡូវ** (Hassan Jallow) អគ្គព្រះរាជអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់ប្រទេសរ៉្វាន់ដា **ស្ទីវិន រ៉ាប់** (Stephen Rapp) អគ្គព្រះរាជអាជ្ញានៃតុលាការពិសេសសំរាប់សារ៉ាឡេអូន និង **ហ្វាទូ បិនស៊ូដា** (Fatou Bensouda) អគ្គព្រះរាជអាជ្ញារងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍ នៅទីក្រុងឡាអេ ។

ដោយយកតាមលំនាំនៃសន្និសីទពីពេលមុនៗដែលបានធ្វើឡើងនៅ អារូសា ប្រទេសតង់ហ្សានៀ កាលពីឆ្នាំ២០០៤ នៅហ្វ្រីថោន សារ៉ាឡេអូន ក្នុងឆ្នាំ២០០៥ និងនៅទីក្រុងឡាអេ ប្រទេសនីឌែរឡែន ក្នុងឆ្នាំ២០០៦ សន្និសីទលើកនេះនឹងលើកយកបញ្ហាបច្ចុប្បន្ន និងកង្វល់នានាជាសកលដែលកំពុងប្រឈមមុខដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ សន្និសីទនេះនឹងផ្តល់នូវការកំណត់មួយ ចំពោះព្រះរាជអាជ្ញាអន្តរជាតិជាន់ខ្ពស់ ដើម្បីផ្លាស់ប្តូរគំនិតផ្សេងៗ ព្រមទាំងផ្តល់នូវឱកាសដែលមានតែមួយគត់ ក្នុងការស្វែងរកកិច្ចពិភាក្សានៅលើប្រធានបទដ៏មានសារសំខាន់ នៅក្នុងកិច្ចអភិវឌ្ឍន៍ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និង ការកាត់សេចក្តីដោយជោគជ័យទៅលើជនល្មើសទាំងឡាយដែលរំលោភបំពានលើច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខ័ណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ ៧១
ទូរស័ព្ទលេខ + ៨៥៥ (០) ២៣ ២១៩ ៨១៤ ទូរសារលេខ + ៨៥៥ (០) ២៣ ២១៩ ៨៤១ Web: www.eccc.gov.kh

ស្ថាប័នទាំងប្រាំ(៥)នេះ ដែលនឹងមានវត្តមាននៅក្នុងការពិភាក្សាផ្លាស់ប្តូរយោបល់នោះសុទ្ធតែទទួលបន្ទុកក្នុងការកាត់សេចក្តីជនដែលដល់នានាដែលប្រព្រឹត្តបទឧក្រិដ្ឋដ៏ធ្ងន់ធ្ងរបំផុត ដែលរួមមាន បទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ព្រះរាជអាជ្ញានឹងប្រើប្រាស់ការពិភាក្សាផ្លាស់ប្តូរយោបល់នេះដើម្បីបន្តខិតខំប្រឹងប្រែង ដើម្បីធានាឲ្យជនទាំងឡាយដែលទទួលខុសត្រូវចំពោះការរំលោភបំពានលើសិទ្ធិជាមូលដ្ឋានដ៏សំខាន់ជាងគេបំផុតរបស់មនុស្សជាតិត្រូវបាននាំខ្លួនទៅឲ្យតុលាការកាត់ទោស ដោយមិនគិតអំពីពេលវេលា និង ទីកន្លែងដែលអំពើដ៏សាហាវយង់ឃ្នងបានកើតឡើងនោះទេ ។

ទម្រង់នៃអង្គសន្និសីទនេះ នឹងត្រូវរួមបញ្ចូលនូវការប្រារព្ធពិធីបើកអង្គសន្និសីទ ការពិភាក្សាតុមូលជាសាធារណៈ ដែលមានចំណងជើងថា “នៅទីកន្លែងនេះ និងក្នុងពេលឥឡូវនេះ: បញ្ហាប្រឈមមុខនានាបច្ចុប្បន្នរបស់ព្រះរាជអាជ្ញាអន្តរជាតិ” ការធ្វើដំណើរទស្សនាចរអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (អ.វ.ត.ក) និង អង្គប្រជុំជាសម្ងាត់មួយចំនួននៅលើប្រធានបទផ្សេងៗដែលមានសារៈសំខាន់ៗជាពិសេសសម្រាប់ស្ថាប័ននីមួយៗ ។

កិច្ចពិភាក្សតុមូលនឹងប្រព្រឹត្តទៅនៅចន្លោះពេលពីម៉ោង **០៩:០០ ដល់ម៉ោង ១១:៣០ នៅ ពុធថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ ២០០៧ នៅក្នុងសាលសវនាការធំនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (អ.វ. ត.ក)** ។ នេះគឺជាសម័យប្រជុំតែមួយគត់នៃសន្និសីទពិភាក្សាផ្លាស់ប្តូរយោបល់ដែលបើកចំហរដល់សាធារណៈជន ។ ហេតុដូច្នេះ អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា និងព្រះរាជអាជ្ញាអន្តរជាតិ សំណូមពរយ៉ាងទទូចសូមឲ្យសាធារណៈជន និងប្រព័ន្ធផ្សព្វផ្សាយពត៌មាននានាអញ្ជើញចូលរួម ។ បន្ទាប់ពីអង្គពិភាក្សានេះ នឹងមានបើកធ្វើជាសន្និសីទសារព័ត៌មានខ្លីមួយ និងមានឱកាសចូលរួមក្នុងការថតរូបជាក្រុម ឬ ជាបុគ្គលជាមួយព្រះរាជអាជ្ញាដែលបានអញ្ជើញចូលរួម ។ លើសពីនេះ ព្រះរាជអាជ្ញាអន្តរជាតិនឹងត្រៀមលក្ខណៈក្នុងការធ្វើបទសម្ភាសន៍ខ្លីៗជាបុគ្គល ។

អ្នកតំណាងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលមានបំណងចង់យកព័ត៌មានអំពីកិច្ចពិភាក្សាតុមូល និង នៅក្នុងសន្និសីទសាព័ត៌មាន សូមស្នើឱ្យបញ្ជាក់អះអាងអំពីវត្តមានរបស់ខ្លួន តាមរយៈអ៊ីម៉េល 4th_Prosecutors_Colloquium @un.org ឬ តាមរយៈទូរស័ព្ទលេខ (៨៥៥) ០២៣ ២១៩ ៨១៤ តទៅលេខ ៦២៤០ (ជាភាសាអង់គ្លេស) ឬ ៦០៣២ (ជាភាសាខ្មែរ) មិនឱ្យហួសពីថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ២០០៧ នេះ ។


ECCC, National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia
Tel: +(855) 023 219 814 Fx: +(855) 023 219 841 Web: www.eccc.gov.kh